**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...៣០៥...សហវ.ប្រក.ពជ

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០០៨

# សារាចរណែនាំ

## ស្តីពីនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាទាក់ទិននឹងពន្ធលើដីធ្លីមិនប្រើប្រាស់

ក្នុងការអនុវត្តន៍បទប្បញ្ញត្តិនៃច្បាប់ស្តីពីដីធ្លីមិនបានប្រើប្រាស់ កម្មសិទ្ធករមួយចំនួនដែលជាអ្នកជាប់ពន្ធលើដីមិនបានប្រើប្រាស់ បំពេញកាតព្វកិច្ចសារពើពន្ធខ្លួនមិនបានត្រឹមត្រូវ និងទាន់ពេលវេលាតាមច្បាប់គំរូវឡើយ។ អ្នកជាប់ពន្ធលើដីធ្លី មិនបានប្រើប្រាស់មួយចំនួនដោយមានតំរូវការចំបាច់ទាក់ទិននឹងដីធ្លីរបស់ខ្លួន ទើបចូលខ្លួនមកទាក់ទងជាមួយរដ្ឋបាលសារពើពន្ធ និងលើកមូលហេតុច្រើនបែបច្រើនយ៉ាងសំរាប់អន្តរាគមន៍សុំការអនុគ្រោះ ដូចជាអ្នកជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ខ្លះសុំបន្ថយរយៈពេលជាប់ពន្ធ ខ្លះទៀតសុំអនុគ្រោះលើកលែងទោសទណ្ឌ ខ្លះតវ៉ាមិនព្រមបំពេញកាតព្វកិច្ចសារពើពន្ធ ដោយលើកសំអាងថា បានប្រើប្រាស់ដីក្នុងការបង្ករបង្កើនផលជាដើម ... ។

ក្នុងការតវ៉ាទាក់ទិននឹងអត្តសញ្ញាណដីធ្លីមិនបានប្រើប្រាស់ ឬស្នើលើកលែងទោសទណ្ឌ ឬសុំបន្ថយរយៈពេលជាប់ពន្ធលើដីមិនបានប្រើប្រាស់ អ្នកជាប់ពន្ធខ្លះអនុវត្តមិនបានត្រឹមត្រូវតាមនីតិវិធីសារពើពន្ធ និងពុំមានឯកសារសំអាងជាក់លាក់សំរាប់ពិចារណាថ្លឹងថ្លែងក្នុងការដោះស្រាយឡើយ។ ដូចនេះក្នុងគោលបំណងដើម្បីដោះស្រាយការតវ៉ារបស់អ្នកជាប់ពន្ធលើដីមិនបានប្រើប្រាស់ អោយបានឆាប់រហ័សនិងមានមូលដ្ឋានជាក់លាក់នោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមកំណត់ជូនដូចតទៅៈ

១- ខ្លឹមសារបណ្តឹងតវ៉ាៈ

ពាក្យតវ៉ាត្រូវមានចែងអំពីខ្លឹមសារដូចខាងក្រោមៈ

- អត្តសញ្ញាណនិងអសយដ្ឋានរបស់អ្នកជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ដែលធ្វើពាក្យតវ៉ា
- សេចក្តីយោងទៅរកការកំណត់ សេចក្តីសំរេច ឬលទ្ធផលដែលជាកម្មវត្ថុនៃការតវ៉ា
- ដើមហេតុ ឬអំពើដែលជាកម្មវត្ថុនៃការតវ៉ា
- ហេតុផលនៃការតវ៉ា
- កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកជាប់ពន្ធ ឬហត្ថលេខារបស់អ្នកតំណាងមានការអនុញ្ញាតិរបស់អ្នកជាប់ពន្ធ។

ផ្លូវលេខ ៩២ សង្កាត់ វត្តភ្នំ ខ័ណ្ឌដូនពេញ កម្ពុជា
St.92 Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទៈ ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារៈ ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

២- វិធានការនៃបណ្តឹងតវ៉ា:

ក- អ្នកជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់មិនយល់ព្រមនឹងការកំណត់ពន្ធ ឬសេចក្តីសំរេចដែលធ្វើឡើងដោយមន្ត្រីពន្ធដារនៃសាខាពន្ធដារខេត្ត/ក្រុង អាចធ្វើការតវ៉ាទៅប្រធានសាខាពន្ធដារខេត្ត/ក្រុងពិនិត្យសំរេច ។

ខ- ប្រសិនបើអ្នកជាប់ពន្ធលើដីធ្លីមិនប្រើប្រាស់ នៅតែមិនយល់ព្រមនិងការកំណត់ពន្ធ ឬសេចក្តីសំរេចដែលធ្វើឡើងដោយប្រធានសាខាពន្ធដារខេត្ត/ក្រុង អាចធ្វើការតវ៉ាទៅប្រធាននាយកដ្ឋានពន្ធដារ ពិនិត្យសំរេច ។

ចំពោះសំណុំឯកសារតវ៉ាដែលដាក់ជូនប្រធាននាយកដ្ឋានពន្ធដារពិនិត្យសំរេច ត្រូវរៀបចំជាកំណត់បង្ហាញសង្ខេបរឿង ដោយមានភ្ជាប់ជាមួយនូវឯកសារ ឬបន្ទុកភស្តុតាងដែលជាសំអាងនៃការតវ៉ា និងត្រូវមានការផ្តល់មតិពីប្រធានសាខាពន្ធដារខេត្ត/ក្រុង ។

គ- ប្រសិនបើអ្នកជាប់ពន្ធលើដីធ្លីមិនប្រើប្រាស់ នៅតែមិនយល់ព្រមនឹងការកំណត់ពន្ធ ឬសេចក្តីសំរេចដែលធ្វើឡើងដោយប្រធាននាយកដ្ឋានពន្ធដារទៀត អាចធ្វើការតវ៉ាទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិនិត្យសំរេច ។

សំណុំឯកសារតវ៉ាដែលបានដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យសំរេច ត្រូវរៀបចំជាកំណត់បង្ហាញសង្ខេបរឿងដោយមានភ្ជាប់ជាមួយនូវឯកសារ ឬបន្ទុកភស្តុតាងដែលជាសំអាងនៃការតវ៉ា នឹងត្រូវមានការផ្តល់មតិពីប្រធាននាយកដ្ឋានពន្ធដារ និងប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

រាល់ដំណោះស្រាយនៃការតវ៉ាដែលទាក់ទិននឹងការលើកលែងពន្ធ ឬបន្ធូរបន្ថយពន្ធ ត្រូវសំរេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំពោះការតវ៉ាទាំងឡាយណាទាក់ទិននឹងពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដែលបានអនុវត្តតាមការកំណត់ខាងលើនេះ នឹងមិនត្រូវទទួលយកមកពិនិត្យដោះស្រាយឡើយ ។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

<u>**កន្លែងទទួល:**</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង_រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត_ក្រុង
  " ដើម្បីជូនជ្រាបជាព័ត៌មាន "
- គ្រប់អង្គភាពពន្ធដារ " ដើម្បីអនុវត្ត "
- កាលប្បវត្តិ